ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក
ស
វ



# Work Activities

ប្រចាំខែមករា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពីស្ថិតិ | ៣ |
| ៣- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៥ |
| ៤- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៤ | ៨ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៦ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើត ការរំលាយចោល និងការកំណត់តួនាទីនិងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក

កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីបានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរំលាយចោល និងការកំណត់តួនាទីនិងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិកនិងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាង ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងធនធានទឹក និងឧតុនិយម។



ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំកែសម្រួលបំពេញបន្ថែម និង លុបចោលខ្លឹមសារខ្លះក្នុងសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរំលាយចោល និង ការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក ដែលធ្លាប់បាន ដាក់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីពេលកន្លងមក។ ការកែសម្រួលគឺផ្តោតទៅលើមាត្រា ៣៥ នៃសេចក្តីព្រាងអនុក្រឹត្យនេះ ដោយកែសម្រួលយ៉ាងឲ្យអនុវត្តបាន។ មាត្រា ៣៥ ចែងពីរូបមន្តសម្រាប់គណនាថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ រូបមន្តនេះមានភាពស្មុគស្មាញក្នុងការគណនា និងការប្រមូលថ្លៃទឹកនេះធ្វើឲ្យប៉ះពាល់ដល់ជីវភាព និងសតិអារម្មណ៍ប្រជាកសិករយ៉ាងខ្លាំង។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរំលាយចោលនិងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក មានគោលបំណងធានាបាននូវការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកប

ដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានគោលដៅកំណត់ពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក ដែលមានវិសាលភាពអនុវត្តចំពោះសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក។

## សេចក្តីព្រាងច្បាប់ស្តីពី

# ស្ថិតិ

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **តាល់ ណៃរ៉ាម** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុខ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីស្ថិតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិកនិងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



ច្បាប់ស្តីពីស្ថិតិដែលបានចូលជាធរមានកាលពីឆ្នាំ២០០៥ កន្លងមក ជាលទ្ធផលគឺបានផ្តល់នូវមូលដ្ឋានគតិយុត្តប្រកបដោយសក្តានុពល អនុញ្ញាតឲ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការអាចប្រតិបត្តិការយ៉ាងទូលំទូលាយពេញទូទាំងប្រទេស ប្រកបដោយជោគជ័យ ក្នុងការផលិតទិន្នន័យស្ថិតិស្ទើរគ្រប់វិស័យ តាមវិធីសាស្រ្តបច្ចេកទេសទំនើប គឺការធ្វើអង្កេត ដើម្បីទទួលបានទិន្នន័យស្ថិតិត្រឹមត្រូវ ជឿទុកចិត្តបាន និងទាន់ពេលវេលា ជូនអ្នកប្រើប្រាស់ជាតិនិងដៃគូអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព សម្រេចបានតាមគោលដៅជាក់លាក់។ កិច្ចសហប្រតិបត្តិការក្នុងការផលិតទិន្នន័យស្ថិតិនាពេលកន្លងមក អាចប្រព្រឹត្តទៅបានដោយមានការជួយឧបត្ថម្ភទាំងបច្ចេកទេស ព្រមទាំងថវិកាមួយចំណែកធំ គឺដៃគូអភិវឌ្ឍន៍ ហើយសំខាន់គឺ ក្រោយពីការធ្វើកំណែទម្រង់ពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារ។

មុខងារស្ថិតិមានអត្ថប្រយោជន៍សំខាន់ណាស់ក្នុងការកំណត់គោលនយោបាយ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ប្រជាសាស្ត្ររបស់ប្រទេស ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងកិច្ចអភិវឌ្ឍ។ ក្នុងយុគសម័យនៃការរីកចម្រើនផ្នែកព័ត៌មានវិទ្យា ព័ត៌មាននិទ្ទន័យស្ថិតិ ត្រូវបានឲ្យតម្លៃខ្ពស់ ហើយបានក្លាយទៅជាឧបករណ៍ដ៏ចាំបាច់បំផុតសម្រាប់តាមដាន ត្រួតពិនិត្យវាយតម្លៃអំពីស្ថានភាពនៃការវិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្ររបស់ប្រទេសទាំងឡាយលើពិភពលោក។ បើគ្មានស្ថិតិ យើងមិនអាចយល់ដឹងពីព័ត៌មានសម្រាប់យកមកធ្វើការតាមដាន ត្រួតពិនិត្យ វិភាគ និងវាយតម្លៃ ក្នុងការធ្វើសេចក្តីសម្រេចកសាងផែនការ



យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍចំគោលដៅប្រកបដោយប្រសិទ្ធភាពបានទេ ទិន្នន័យស្ថិតិជាឧបករណ៍ចាំបាច់បំផុតរបស់អ្នកធ្វើផែនការអភិវឌ្ឍ។ បើគ្មានទិន្នន័យស្ថិតិទាន់ពេលវេលានោះទេ យើងក៏មិនអាចធ្វើការប្រកួតប្រជែងបានដែរ។

ក្នុងគោលដៅបន្តនិរន្តរភាពផលិតទិន្នន័យស្ថិតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អ្នកប្រើប្រាស់ស្ថិតិ ពិសេសអ្នកធ្វើសេចក្តីសម្រេចចិត្ត ធ្វើផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ក៏ដូចដៃគូអភិវឌ្ឍន៍នានា សម្រាប់ទៅអនាគត វិទ្យាស្ថានស្ថិតិដោយមានការផ្តល់ប្រឹក្សាពីអ្នកជនាញការស្ថិតិស៊ុយអែត( SIDA ) បានរៀបចំសេចក្តីព្រាងច្បាប់ថ្មីនេះឡើង។ សេចក្តីព្រាងច្បាប់ស្តីពីស្ថិតិនេះ ក៏ត្រូវបានតាក់តែងឡើងដោយមានកិច្ចសហការជាមួយនឹងបណ្តាលប្រទេសនានាដែរមានប្រព័ន្ធស្ថិតិរឹងមាំ រីកចម្រើន ពិសេសគឺការផ្តល់អនុសាសន៍របស់អ្នកជំនាញការស្ថិតិអង្គការParis21( សាធារណរដ្ឋបារាំង ) ដែលធ្លាប់មានបទពិសោធន៍យ៉ាងច្រើនលើជំនួយបច្ចេកទេសក្នុងការធ្វើបទប្បញ្ញត្តិស្ថិតិក្នុងពិភពលោក[១]។

សេចក្តីព្រាងច្បាប់នេះ ក៏បានឆ្លងសម្រេចនិងឯកភាពពីអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងអង្គវេទិកាថ្នាក់ជាតិស្តីពីការគាំទ្រវិស័យស្ថិតិ អ្នកចូលរួមមានមន្ត្រីមកពីគ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងក្រុមហ៊ុននានា រួចរាល់ហើយផងដែរ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីស្ថិតិ។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃថ្ងៃអង្គារ ទី២៧ ខែមករា ឆ្នាំ២០១៥ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌(ECOSOCC) ឯកឧត្តម **ឌុយ ឆៅ** អនុប្រធាន ECOSOCC ព្រមទាំងសមាជិក ECO-SOCC ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួន របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់។

៣- បញ្ហាផ្សេងៗ





ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក៖

អង្គប្រជុំបានពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងល្អិតល្អន់ និងបានសម្រេចកែសម្រួលពាក្យពេចន៍និងខ្លឹមសារដូចជា៖

មាត្រា២ កថាខណ្ឌទី១ បន្ទាត់ទី១ លុបឃ្លា "**និងការកំណត់**" ជំនួសដោយឃ្លា "**ហើយនិង**" បន្ទាប់ពីពាក្យ "**ការរំលាយចោល**"។

មាត្រា៥ ត្រេទី៤ បន្ថែមឃ្លា "**និងចូលរួមផ្សព្វផ្សាយឲ្យបានទូលំទូលាយ**" នៅចុងឃ្លា។

មាត្រា១៦ បន្ថែមកថាខណ្ឌចុងក្រោយ "**តំណាង ស.ក.ប.ទ. មួយរូបត្រូវមានតួនាទីជាអនុប្រធានសហគមន៍កសិកម្មជាស្វ័យប្រវត្តិ ក្នុងករណីដែលមូលដ្ឋាននោះ មានសហគមន៍កសិកម្ម ហើយក្នុងករណីនេះ តំណាងសហគមន៍កសិកម្មមួយរូបត្រូវមានតួនាទីជាអនុប្រធាន ស.ក.ប.ទ. ជាស្វ័យប្រវត្តិវិញ**"។

ទន្ទឹមនឹងនេះ អង្គប្រជុំបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអ្នកច្បាប់ពិនិត្យលើការបន្ថែមកថាខណ្ឌចុងក្រោយខាងលើនេះ ជៀសវាងការខ្វាស់នឹងច្បាប់ស្តីពីសហគមន៍កសិកម្ម។

មាត្រា៣១ ត្រេទី៧ លុបឃ្លា "**តាមរយៈក្រសួងធនធានទឹក និងឧតុនិយម**"។

មាត្រា៣៥ អង្គប្រជុំបានសម្រេចយកជម្រើសពីរដាក់ឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច៖

- ជម្រើសទី១ មិនឲ្យមានការបង់ថ្លៃសេវាកម្មប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។
- ជម្រើសទី២ កែសម្រួលទៅជា "**គណៈកម្មាធិការ ស.ក.ប.ទ. មានភារកិច្ចប្រមូលភាគទានពីអ្នកប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រទាំងអស់ ដើម្បីបម្រើឲ្យកិច្ចដំណើរការថែទាំ និងជួសជុលបណ្តាញធារាសាស្ត្ររបស់ខ្លួន។ នីតិវិធីនិងរូបមន្តក្នុងគណនាភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**"។

ក្រៅពីនេះ រាល់ពាក្យ "**ថ្លៃសេវាកម្ម**" ជំនួសដោយពាក្យ "**ភាគទាន**" នៅគ្រប់មាត្រាដែលប្រើពាក្យ "**ថ្លៃសេវាកម្ម**" ទាំងអស់។

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួន របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់៖

- អង្គប្រជុំ បានឯកភាពលើទម្រង់និងខ្លឹមសាររួមរបស់សេចក្តីព្រាងអនុក្រឹត្យនេះ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះ នៅវេលាម៉ោង ១១:៣៥នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១៤



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➤ អត្រាអតិផរណាឆ្នាំ២០១៤ស្មើនឹង ៣,៩% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រាមធ្យមនេះមានម្ហូបអាហារ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ គ្រឿងសង្ហារឹម សុខាភិបាល ការសិក្សា និងភោជនីយដ្ឋាន។

តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ។

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ ២០១៤ | អត្រារួមចំណែក | អតិផរណាឆ្នាំ ២០១៣ |
|---|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ៣,៩% | ១០០% | ៣,០% |
| ១ | ម្ហូបអាហារ | ៤,៩% | ៥៥% | ៣,៩% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ៥,៧% | ២,៤% | ៣,១% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ២,២% | ១,៧% | ៤,៧% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន ... | ២,៨% | ១២,០% | ០,៧% |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ៧,៣% | ៥,២% | ៣,០% |
| ៦ | សុខាភិបាល | ៤,៣% | ៥,៨% | ៥,១% |
| ៧ | ការដឹកជញ្ជូន | -១,០% | -៣% | -០,៦% |
| | ក្នុងនោះ ប្រេងសាំង | -៣,០% | -៤% | -០,៨% |
| ៨ | ទូរគមនាគមន៍ | -២,៧% | -០,៨% | -១,៥% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | ៣,៥% | ២,៦% | ៤,៨% |
| ១០ | ការសិក្សា | ៥,៣% | ១,៦% | ៥,០% |
| ១១ | ភោជនីយដ្ឋាន | ៧,០% | ១១% | ៥,៥% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងៗ | -៣,៧% | -២,២% | -២,៦% |



⇨ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមានការដឹកជញ្ជូន ទូរគមនាគមន៍ និងទំនិញនិងសេវាកម្មផ្សេងៗ។

តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ២០១២-២០១៤(ដែលជាការឡើងនៃថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ខែដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ១,១% | ៣,៩% |
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,២% | ៤,៧% | ៣,០% |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៨% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មានផ្លែឈើ៩,៧% សាច់ជ្រូក៩,១%សាច់គោស្រស់ ៦,៧% និងត្រីស្រស់៥,៦% ។

**➢អត្រាប្ដូរប្រាក់៖**

⇨ជារួមប្រាក់រៀលមានការធ្លាក់ថ្លៃបន្តិចបន្តួចធៀបនឹងរូបិយប័ណ្ណបរទេស។នាចុងឆ្នាំ២០១៤អត្រាប្ដូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួនមានស្ថានភាពដូចខាងក្រោម៖

- ប្រាក់រៀលធ្លាក់ថ្លៃ**២%**ធៀបនឹងដុល្លារអាមេរិក និងមានអត្រា៤,០៧៥៛/ដុល្លារ
- ប្រាក់រៀលធ្លាក់ថ្លៃ**១,៦%** ធៀបនឹងបាតថៃ និងមានអត្រា១២៤៛/បាត
- ប្រាក់រៀលធ្លាកថ្លៃ **០,៥%** ធៀបនឹងដុងវៀតណាមនិងមានអត្រា០,១៩១៛/ដុង។

## ២) ស្ថានភាពថវិកាជាតិ

➢យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៤នេះ អនុវត្តបានចំនួន ១០៩៣៦,៤ ពាន់លានរៀល ស្មើនឹង ១០៣% នៃច្បាប់ថវិកា ក្នុងនោះចំណូលចរន្ត ៩២៣៩,៣ ពាន់លានរៀល ស្មើនឹង ១០៩% នៃច្បាប់ថវិកា និងចំណូលមូលធន ២០០,៨ពាន់លានរៀល។

➢ បើធៀបនឹងឆ្នាំ ២០១៣ ចំណូលថវិកាជាតិកើនឡើង ២២% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង១១% និង ចំណូលមូលធនថយចុះ ៤២%។

⇨ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្ដាលមកពីចំណូលសារពើពន្ធកើនឡើង២៥% និងចំណូលមិនមែនសារពើពន្ធកើនឡើង២៤%។

| មុខចំណូល | អនុវត្តច្បាប់ថវិកា | %Δធៀបនឹងឆ្នាំ២០១៣ |
|---|---|---|
| **ចំណូលសារពើពន្ធ** * | ១០៩% | +១១% |
| ✓**ពន្ធ និងអាករគយ** ** | ១១៨% | +៣៤% |
| –ពន្ធគយ (របបនាំចូល) | ១១៤% | +៣២% |
| –អាករពិសេសលើរបបនាំចូល | ១២០% | +៤៨% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១២១% | +៣០% |
| –អាករនាំចេញ | ១៣៨% | +១២% |
| –អាករបន្ថែមលើគេលសិលា | ៩២% | ១២% |
| ✓**ចំណូលពន្ធដារ** *** | ១០៧% | +២០% |
| –ពន្ធលើប្រាក់បៀវត្ស | ១១៩% | +៣១% |
| – ពន្ធលើប្រាក់ចំណេញ | ១០៧% | +២៥% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ១៣៩% | +៤០% |
| – អាករលើផលរបរ | ៨៦% | +២% |
| – អាករលើតម្លៃបន្ថែម | ១០៥% | +១៥% |
| –អាករពិសេស | ៩៥% | +១៣% |
| –ពន្ធថវិកាខេត្តរាជធានី | ១០៨% | +១៩% |
| ✓**ចំណូលសារពើពន្ធផ្សេងៗ** * | ៩៤% | +៤% |
| –ចំណូលពីកាស៊ីណូ | ១០៧% | +៥% |
| –ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ១០៧% | +៦៥% |
| –កម្រៃការគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៨៥% | -២% |

| មុខចំណូល | អនុវត្តច្បាប់ថវិកា | %Δធៀបនឹងឆ្នាំ២០១៣ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** * | ៩៤% | +២៤% |
| ✓នេសាទ | ៩៣% | +២% |
| ✓ រុក្ខាប្រមាញ់ | ១១៣% | -១៣% |
| ✓សម្បទានរ៉ែ | ១៨% | +១១% |
| ✓អាកាសចរណ៍ស៊ីវិល | ១០០% | +៤៣% |
| ✓ ផលទុនទេសចរណ៍ | ៤៩% | -៨% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៨១% | -២៣% |
| (១) | ៨៩% | +២១% |
| ✓អាករស្ថានទូត | ១៣០% | +១១% |
| ✓ ត្រួតពិនិត្យគុណភាពផលិតផល | ១០០% | +២១% |
| ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | ០% | -១០០% |
| ✓ឯកជនភាវូបនីយកម្ម | ១២៤% | -២៧% |
| ✓ ការលក់អចលនកម្ម | | |

* តួលេខរតនាគាជាតិ ** តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ***តួលេខអគ្គនាយកដ្ឋានពន្ធដារ

(១) បើតាមតួលេខជាក់ស្តែងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំណូលអនុវត្តបាន ៩៣% នៃច្បាប់ថវិការ កើនឡើង ១១.៦% ធៀបនឹងឆ្នាំ២០១៣។

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៤ អនុវត្តបាន៨៦៦៤,៤ ពាន់លានរៀល ស្មើនឹង ៦៤% នៃច្បាប់ថវិកា ក្នុងនោះ ចំណាយចរន្ត ៧១៤៧,៣ពាន់លានរៀលស្មើនឹង ៨៦% នៃច្បាប់ថវិកា និងចំណាយមូលធន ១៥១៧ពាន់លានរៀល។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង ២៩,៥%ក្នុងនោះចំណាយចរន្តកើនឡើង ៣២%និងចំណាយមូលធនកើនឡើង១៧%។

➢ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០១៤ មានអតិរេកចំនួន ១៨៧២ ពាន់លានរៀល។ប៉ុន្តែគួរកត់សម្គាល់ថាតារាងទិន្នន័យថវិការជាតិបង្ហាញតែតួលេខចំណាយមូលធនដែលឆ្លងកាត់រតនាគារជាតិប៉ុណ្ណោះ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៤មានសូចនាកររូបិយវត្ថុដូចខាងក្រោម៖

⇨រូបិយវត្ថុ *M2* មានចំនួន៤២៥៦០ពាន់លានរៀលកើនឡើង២៩,៩% ធៀបនឹងឆ្នាំ២០១៣។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៤**(% នៃរូបិយវត្ថុទូទៅ*M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៣**




⇨សមាសធាតុរូបិយវត្ថុមិនសូវមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ទេ។ រូបិយវត្ថុក្រៅធនាគារថយចុះពី១៣,៦% នៃM2ក្នុងឆ្នាំ២០១៣មក ១៣,១% នៃM2ក្នុងឆ្នាំ២០១៤។ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេសកើនឡើងពី ៨២,២% មក ៨២,៨% នៃM2។

⇨តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០១០-២០១៤)

| | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| *M2* | +២០% | +២១% | +២១% | +១៥% | +២៩,៩% |
| *M1* | +៣% | +២៣% | +២% | +២១% | +២៩,៣% |
| រូបិយវត្ថុក្រៅធនាគារ | +៣% | +២២% | 0 | +១៩% | +២៥,៦% |
| ប្រាក់បញ្ញើចរន្ត | +៣% | +៥១% | +៥៧% | +៤៦% | +៦៨,៥% |
| រូបិយវត្ថុផ្សេងៗ | +២៤% | +២១% | +២៥% | +១៤% | +៣០% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +១៤% | +៣៦% | +៤០% | +២១% | +១៥,៣% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +២៤% | +២១% | +២៤% | +១៣% | +៣០,៥% |

⇨ក្នុងឆ្នាំ២០១៤ រូបិយវត្ថុទូទៅ*M2* មានការកើនឡើងខ្ពស់ជាងឆ្នាំមុនៗ។ *M2* មានចំនួនប្រហែល ៦៣% នៃផសស ប៉ុន្តែ**សមមាត្រ***M1* ក្នុងផសស មានត្រឹមតែ ៩,៣% ប៉ុណ្ណោះ។ ក្នុងអំឡុងពេលបួនឆ្នាំចុងក្រោយប្រាក់បញ្ញើចរន្តមានការកើនឡើងគួរឲ្យកត់សម្គាល់។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន៤២៩២ លានដុល្លារកើនឡើង២៤,១%ធៀបនឹងឆ្នាំ ២០១៣។

➢ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន១២០០៨ ពាន់លានរៀលកើនឡើង ១៤,៦%បើធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន៣៨៨៣៩ពាន់លានរៀលកើនឡើង ៣០,២%ធៀបនឹងឆ្នាំមុន។

➢ ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន៨២១៩ពាន់លានរៀល កើនឡើង ៥៦,២% ។

➢អត្រាការប្រាក់ប្រចាំឆ្នាំ៖

| ប្រភេទអត្រាការប្រាក់ | អត្រាឆ្នាំ២០១៤ | អត្រាឆ្នាំ២០១៣ | %Δ (២០១៤/២០១៣) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០៨% | ៥,៨% | +៣,៨% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២៦% | ១៥,៧២% | +៣,៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៣% | ៤,២៧% | -១% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥១% | ១១,៣៥% | +១,៤% |
| កម្ចីជារៀលនៅហត្ថកសិករ | ៣១,២% | ៣១,២% | 0% |
| កម្ចីជារៀលនៅអម្រឹត | ៣១,៨% | ៣២,១% | -0,៩% |
| កម្ចីជារៀលនៅស្ថាបនា | ៣១,២% | ៣១,២% | 0% |
| កម្ចីជារៀលនៅប្រាសាក់ | ២៥,៨% | ៣១,៨% | -១៨,៩% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢*កសិកម្ម៖*

➩ក្នុងឆ្នាំ២០១៤ផលិតផលស្រូវមានបរិមាណ ៩២៣៤ពាន់តោន មានការថយចុះ ១,៧% បើធៀបនឹងឆ្នាំ២០១៣ រីឯទិន្នផលមានចំនួន៣,០៥តោន/ហិកតាមានការថយចុះ៣,៥% ធៀបនឹងឆ្នាំ ២០១៣។







➩ក្នុងឆ្នាំ ២០១៤ ការដាំស្រូវទាំងពីររដូវបានធ្វើលើផ្ទៃដីចំនួន ៣០៥២ពាន់ហិកតា ច្រើនជាងឆ្នាំ២០១៣ចំនួន ១២ពាន់ហិកតា។

➩ក្នុងឆ្នាំ២០១៤ ផលិតផលកៅស៊ូមានចំនួន៩៦,៧ពាន់តោន កើនឡើង ១៣,៤% ។ផ្ទៃដីចៀរជ័រមានចំនួន ៩០,៦ ពាន់ហិកតា និងផ្ទៃដីដាំដុះសរុបមាន ៣៥៧,៨ ពាន់ហិចតា។

➩ ផលិតកម្មនេសាទឆ្នាំ២០១៤ មានចំនួន ៦៧៦ ពាន់តោនមានការថយចុះ៥%ធៀបនឹងឆ្នាំ២០១៣។

➢*ឧស្សាហកម្ម៖*

➩ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៤៥៦៩,៩ GWh កើនឡើង ២១% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ១៨៤០,៩ GWh កើនឡើង ៨៣%។

➩ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន៥៧១៩,៨លានដុល្លារកើនឡើង១៣%។

➩ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ១៨៨,២លានម៣ កើនឡើង៨%។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម:**

| *ប្រភេទ* | *ចំនួន :២០១៤* | *ចំនួន:២០១៣* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១៣១៧ | ១១២០ | +១៨% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៩៧ | ២១១ | -៧% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៥៦ | ២៤៦ | -៣៦% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | - | ១៥១ | - |

⇨**សំណង់ (ការអនុញ្ញាត)៖**

- ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១៤ មានទឹកប្រាក់ស្មើនឹង ២៥០៧.២លានដុល្លារ ថយចុះ១០% ធៀបនឹងឆ្នាំ ២០១៣។

| *ប្រភេទសំណង់* | ពាន់ម² :២០១៤ | ពាន់ម² :២០១៣ | % ∆ |
|---|---|---|---|
| លំនៅឋាន | ៣១៦៥,៧ | ២០៧៥ | +៥៣% |
| ឧស្សាហកម្ម | ១៧២៥,៩ | ១៤៨០ | +១៧% |
| ពាណិជ្ជកម្ម | ៩៧៧,៤ | ៣២០៣ | -៦៩% |
| ទេសចរណ៍ | ៣១៥,២ | ២១០ | +៥០% |
| ... | ... | ... | ... |
| អនុញ្ញាតសរុប | ៦៤៦០,២ | ៧៥៩៦ | -១៥% |

- ក្នុងការអនុញ្ញាតនេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៤៩% នៃផ្ទៃក្រឡាសរុប) និងឧស្សាហកម្ម (២៦,៧% នៃផ្ទៃក្រឡាសរុប) ។

▪**ការងារ៖**

| *ប្រភេទ* | ២០១៤ (នាក់) | ២០១៣ (នាក់) | %∆ |
|---|---|---|---|
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៧៤២៥៦ | ៥៣៨៦៨ | +៣៨% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៥៤២៦៩ | ៣៣៨២៤ | +៦០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៩៩៩៧ | ១៨៧៤២ | +៧% |

▪ **វិនិយោគ៖**គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក./គ.ជ.នា ក្នុងឆ្នាំ២០១៤ (ថ្មី និងពង្រីក) មានចំនួន ២១០គម្រោង។ ជាទុនវិនិយោគមានទឹកប្រាក់ **៣៩៣៣,៤**លានដុល្លារ និងអាចផ្តល់ការងារបាន ២៥២,៤ពាន់នាក់។

| *ប្រភេទ* | *២០១៤* | *២០១៣* | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៣៩៣៣ | ៤៩៦២ | -២១% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៦៥ | ១១២៩ | -៧៧% |
| វិស័យឧស្សាហកម្ម<br>(ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ២៨៣៦<br>(២០៣៩) | ១១០៧<br>(១៨៧) | +១៥៦%<br>(+៩៩០%) |
| វិស័យទេសចរណ៍ | ៤៨០ | ១០៦ | +៣៥២% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៣៥៣,៥ | ២៦២១ | -៨៧% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ២១០ | ២២៥ | -៧% |
| **ចំនួនពលករ (ពាន់នាក់)** | ២៥២ | ២៨១ | -១០% |

▪ *សេវាកម្មនិងទេសចរណ៍៖*

➢ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | ២០១៤ ( *ចំនួន* ) | ២០១៣(ចំនួន) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៨៥០ | ៣០១០ | +២៩% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៦៥ | ២៤ | +១៧១% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៤០៦៦ | ២១២១ | +៩២% |

➢ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ៦៤៥៥ពាន់តោនកើនឡើង២១%។ ក្នុងនោះ៖

| *ប្រភេទ* | ២០១៤ (ពាន់តោន) | ២០១៣ (ពាន់តោន) | %Δ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១៩០៣ | ១៤៨៥ | +២៨% |
| កំពង់ផែកំពង់សោម | ៣៩០៩ | ៣០៧៨ | +២៧% |
| កំពង់ផែស្រែអំបិល និងកោះកុង | ១១៥៨ | ១០៧២ | +៨% |
| កំពង់ផែឧកញ៉ាម៉ុង | ១២១៧ | ៨១៤ | +៤៩% |

➢ **អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| *ប្រភេទ* | ២០១៤ (ពាន់នាក់) | ២០១៣(ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៤៨ | ១០៨ | +៣៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៩៩ | ២១៤ | +៣៩% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥១៦៩ | ៤៦០៦ | +១២% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៩៦៦ | ៨៧២ | +១០% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៤៤៩០ | ៤២១០ | +៧% |
| ✓តាមផ្លូវអាកាស | ២២៦២ | ២០១៨ | +១២% |
| ✓ តាមផ្លូវគោក និងទឹក | ២២២៨ | ២១៩២ | +២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៤ មានចំនួន៤២៤៧៣,៥ ពាន់លានរៀលកើនឡើង ១៦% បើធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះ៖

| មានការថយចុះ | មានការកើនឡើង | |
|---|---|---|
| ប្រេងខ្មៅ -៤៦% | ប្រេងសាំង +៩% | ម៉ូតូ+១១% |
| អង្ករ -៦៧% | ប្រេងម៉ាស៊ូត +៩% | ផ្លែឈើនិងបន្លែ+៦៩% |
| បារី -៤% | ឧស្ម័ន +៥% | ជីនិងថ្នាំកសិកម្ម +៤៥% |
| អគ្គិសនីនាំចូលពីប្រទេស | ដែកសំណង់+៣៦% | ភេសជ្ជៈ +៧០% |
| ជិតខាង-២៣% | ស៊ីម៉ង់+៣៧% | ប្រេងឆា +៦០% |
| | រថយន្តសរុប (ជាសាច់ប្រាក់) +២៩% | ប៊ីចេង +១៦៨% |
| | គ្រាក់ទ័រនិងគោយន្ត +៣៧% | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +១១% |
| | គ្រឿងអេឡិចត្រូនិច+៨១% | |

▪**ការនាំចេញ**ឆ្នាំ២០១៤មានចំនួន៣២៦៩៨ពាន់លានរៀលកើនឡើង១៦%ធៀបនឹងឆ្នាំ២០១៣ ក្នុងនោះ៖

| *ទំនិញ* | *%∆ធៀបនឹង-២០១៣* | *ទំនិញ* | *%∆ធៀបនឹង-២០១៣* |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៦៩% | ផលិតផលនេសាទ | –៣១% |
| វាយនភណ្ឌនិងស្បែកជើង | +១០% | កៅស៊ូ | +២៩% |
| អង្ករ | +២% | | |

▪ ក្នុងឆ្នាំ២០១៤ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន*៩៧៧៦ពាន់លានរៀលស្មើនឹង* ២៤៤៤លានដុល្លារ។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| **សូចនាករ** | **បម្រែបម្រួលធៀបនឹងឆ្នាំ ២០១៣** | **ផ្សេងៗ** |
|---|---|---|
| ១. អតិផរណារ | +៣,៩% | អតិផរណាមានកម្រិតទាប |
| ២. ថ្លៃផ្លែឈើ | +៩,៧% | បញ្ហាតម្រូវការនិងការផ្គត់ផ្គង់ |
| ៣. ថ្លៃសាច់ជ្រូក | +៩,១% | បញ្ហាតម្រូវការនិងការផ្គត់ផ្គង់ |
| ៤. ថ្លៃសាច់គោ | +៦,៧% | បញ្ហាតម្រូវការនិងការផ្គត់ផ្គង់ |
| ៥. ចំណាយថវិកាជាតិ | +២៩,៥% | ប៉ុន្តែអនុវត្តបានតែ៦៤% នៃច្បាប់ថវិកា |
| ៦. ទុនវិនិយោគអនុញ្ញាតិក្នុងវិស័យកសិកម្ម និងកសិឧស្សាហកម្ម | -៧៧% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) ជារួមអត្រាអតិផរណាឆ្នាំ២០១៤មានកម្រិតទាប ប៉ុន្តែមុខទំនិញមួយចំនួនដូចជា ផ្លែឈើ សាច់ជ្រូក និងត្រីមានការឡើងថ្លៃគួរឲ្យចាប់អារម្មណ៍។

ការផ្គត់ផ្គង់ក្នុងស្រុកមិនគ្រប់គ្រាន់ជាមូលហេតុចម្បងដែលធ្វើឲ្យសាច់ បន្លែ និងផ្លែឈើ ឡើងថ្លៃខ្ពស់។ ដូច្នេះវិស័យចិញ្ចឹមសត្វគួរតែជាកសិដ្ឋានខ្នាតធំ។ ការទាក់ទាញនិងលើកទឹកចិត្តអ្នកវិនិយោគក្នុងវិស័យកសិកម្ម និងកសិឧស្សាហកម្មជាការចាំបាច់ ដើម្បីបង្កើនផលិតកម្មក្នុងស្រុក កាត់បន្ថយឲ្យបានច្រើននូវការនាំចូល។ ច្បាប់វិនិយោគរបស់កម្ពុជាដែលកំពុងមាន គួរមានការកែតម្រូវខ្លះៗទាក់ទងនឹងការលើកទឹកចិត្ត ដល់អ្នកវិនិយោគខ្នាតធំក្នុងវិស័យនេះ។

២) ចំណូលសារពើពន្ធអនុវត្តបានលើសផែនការនេះជាលទ្ធផលនៃការអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីនិងការសហការគ្នាបានល្អនៃស្ថាប័នពាក់ព័ន្ធ។

៣) នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោយឡែករាជធានីភ្នំពេញមានអំពើចោរកម្មកើតឡើងជាញឹកញាប់ ដូចជាការឆក់និងប្លន់ប្រដាប់អាវុធតាមផ្លូវសាធារណៈស្ទើរតែរាល់ថ្ងៃ ធ្វើឲ្យមានអ្នករងគ្រោះជាច្រើន ទាំងប្រជាពលរដ្ឋក្នុងស្រុក ទាំងភ្ញៀវបរទេស។ បញ្ហានេះពិតជាប៉ះពាល់ដល់សតិអារម្មណ៍ប្រជាពលរដ្ឋ មុខមាត់ប្រទេសទាំងមូល និងសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ។ ក្រសួងមហាផ្ទៃ និងអជ្ញាធរមានសមត្ថកិច្ចក្រោមឱវាទគួរចាត់វិធានការឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីរក្សាសន្តិសុខសង្គម សីលធម៌ និងវប្បធម៌ដ៏ផូរផង់របស់ជាតិយើង។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០១/១៥<br>ម៉ោង០៧:០០នាទី | ចូលរួមក្នុងពិធីមីទ្ទីងអបអរសាទររំលឹកខួបអនុស្សាវរីយ៍លើកទី៣៦ ទិវាមហាជ័យជំនះជាប្រវត្តិសាស្ត្រ៧មករា(០៧-០១-១៩៧៩.០៧-០១-២០១៥) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងលោកជំទាវ នៅសួនច្បារទល់មុខមហោស្រពខេត្តតាកែវ។ |
| ២ | ០៨/០១/១៥<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>២-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា។<br>៣-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៩/០១/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា លើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>២-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា។<br>៣-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៤ | ០៩/០១/១៥ ម៉ោង១៥:៣០នាទី | អនុញ្ញាតឲ្យទូរទស្សន៍ខេត្ត Yunnan ចូលជួបធ្វើបទសម្ភាស នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៤/០១/១៥ ម៉ោង ០៩:០០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីចុះហត្ថលេខាលើសៀវភៅចូលរួមមរណទុក្ខនៅស្ថានទូតបារាំង ចំពោះការបាត់បង់ជីវិតរបស់អ្នកកាសែត ១២នាក់។ |
| ៦ | ២០/០១/១៥ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីទស្សនាការសមទស្សនីភាពសិល្បៈសម្តែងសម្រាប់ពិធីលៀងសាយភោជន៍ ក្នុងសន្និសីទពិភពលោកទេសចរណ៍ និងវប្បធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៧ | ២១/០១/១៥ ម៉ោង ០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ២២/០១/១៥ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៩ | ២២/០១/១៥ ម៉ោង១៥:០០នាទី | ដឹកនាំកិច្ចប្រជុំប្រចាំខែគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិនិត្យលើការងារសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១០ | ២៣/០១/១៥<br>ម៉ោង ០៨:៣០នាទី | ចូលរួមស្តាប់បទបាឋកថាស្តីពីដំណើរការនៃការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរជាតិ ដើម្បីអភិរក្ស និងអភិវឌ្ឍរមណីដ្ឋានប្រវត្តិសាស្ត្រប្រាសាទព្រះវិហារ (ICC-Preah Vihear) ថ្លែងដោយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ២៦/០១/១៥<br>ម៉ោង ០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោល និងការកំណត់ តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋ មន្ត្រី។ |
| ១២ | ២៦/០១/១៥<br>ម៉ោង ១៥:៣០នាទី | អមឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម **សួរ យុន** នៅគេហដ្ឋាននៃសព។ |
| ១៣ | ២៦/០១/១៥<br>ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យជាតិលើកទី៦៦ នៃសាធារណរដ្ឋឥណ្ឌា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ២៧/០១/១៥<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួន របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៨/០១/១៥<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំបូកសរុបការងាររបស់ក្រុមការងារបច្ចេកទេស និងក្រុមហ៊ុន Green Goal ដែលបានអនុវត្តបានកន្លងមក និងដាក់ផែនការការងារដែលត្រូវអនុវត្តបន្ត លើការងារដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ៣០-៣១/០១/១៥<br>០១/០២/១៥<br>ពេញមួយថ្ងៃ | ចូលរួមមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស នៅស្នាក់ការកណ្តាលគណបក្ស និងនៅមជ្ឈមណ្ឌលសន្និបាត និង ពិព័រណ៍កោះពេជ្រ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខៈ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in